**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៣៣ ស.ស.រ**

# សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែមសមាសភាពគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំ នៅខេត្តសៀមរាប

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៣២ សសរ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប

-យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបំពេញបន្ថែមសមាសភាពគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប ដែលមានចែងនៅក្នុងប្រការ១ នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៣២ សសរ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប មានដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ ផេង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២- ឯកឧត្តម **ឌា ជុំប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |

ប្រធានគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាបនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ មកចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តសៀមរាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ខែកក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ